សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale De Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីបង្វែរអនីតិជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **គ្រី លីណា**

លោក **ឡុង ដេវីត**

ណែនាំដោយ

លោក **ប៉ែន ច័ន្ទសុខខេមរិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ត្រី លីណា** និងខ្ញុំបាទឈ្មោះ **ឡុង ដេវីត** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុក និងអ្នកម្តាយ ជាអ្នកមានគុណធំធេង ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ទំនុកបម្រុងកូនតាំងពីតូចបាតជើងក្រហម រហូតដល់កូនអាចបន្តការសិក្សាថ្នាក់បរិញ្ញាបត្រមកដល់សព្វថ្ងៃនេះ ។ បើគ្មានការយកចិត្តទុកដាក់ ថ្នាក់ថ្នម ស្រលាញ់ពីអ្នកមានគុណទេ ម្ល៉េះកូនមិនអាចក្លាយខ្លួនជា កូនល្អ សិស្សល្អ មិត្តល្អ និង ពលរដ្ឋល្អនៅក្នុងសង្គមបានឡើយ នេះជាគុណូបការៈដ៏វិសេសវិសាល ដែលមិនអាចយកអ្វីមកកាត់ថ្លៃបាន ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណដល់ **ឯកឧត្តម លុយ ចណ្ណា ជាសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ ជ្រុមជ្រែង បង្ហាត់បង្រៀន និងចែករំលែកចំណេះដឹងជូនសិស្សនិស្សិតកន្លងមក ។

សូមថ្លែងអំណរគុណ លោក **ម៉ែន ច័ន្ទសុខខេមរិទ្ធ** ដែលជាសាស្ត្រាចារ្យដឹកនាំ ដោយបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដឹកនាំបង្ហាត់បង្ហាញផ្លូវ និងជួយតម្រង់ទិសពួកយើងខ្ញុំ អស់ពីកម្លាំងកាយ កម្លាំងចិត្ត ទោះបីជាលោករវល់កិច្ចការយ៉ាងណាក្តី ក៏ជួយដឹកនាំគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ រហូតដល់សារណានេះបានលេចចេញជារូបរាង។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្តែងសេចក្តីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរជាពិសេសសូមប្រសិទ្ធពរជ័យ សិរីសួស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់ក្នុងដៃនេះគឺជាវណ្ណៈកម្មរបស់ពួកយើងខ្ញុំជានិស្សិតបរិញ្ញាបត្រផ្នែក នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលពួកយើងខ្ញុំបានខិតខំព្យាយាម ស្រាវជ្រាវឡើង ដើម្បីទុកជាស្នាដៃសម្រាប់លោកអ្នក។ ពួកយើងខ្ញុំបានព្យាយាមស្រាវជ្រាវនេះឡើងដោយពួក យើងខ្ញុំបានសម្រេចចិត្ត ក្នុងការជ្រើសរើសយកការសរសេរសារណាបញ្ចប់ការសិក្សា ជំនួសការប្រឡងចេញ វិញ។ ការសរសេរសារណា យើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ សរសេរឡើង ជាសមិទ្ធិផលមួយក្នុងការចែក រំលែកចំណេះដឹង។

យើងខ្ញុំបានជ្រើសរើសប្រធានបទ **នីតិវិធីបង្វែរអនីតិជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ** នេះឡើងព្រោះយើងខ្ញុំបានសិក្សាស្រាវជ្រាវ ដោយមានការយកចិត្តទុកដាក់ និងមានចិត្តចង់យល់ចង់ដឹងបន្ថែម អំពី នីតិវិធីបង្វែរអនីតិជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដើម្បីទុកជាស្នាដៃ ប្រកបដោយការព្យាយាមពីពួក យើងខ្ញុំ ដើម្បីទុកឱ្យប្អូនៗជំនាន់ ក្រោយបានធ្វើការសិក្សាបន្ថែម និងសម្រាប់ការរៀនសូត្រ។ ទោះជានៅក្នុងការ សរសេរសារណាបញ្ចប់ការសិក្សា យើងខ្ញុំបានខិតខំពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយ ក៏នៅតែមានភ្លាំងភ្លាត់ ខុសឆ្គងខ្លះៗ ដោយជាអចេតនាជា ពុំខាន។ ដូច្នេះយើងខ្ញុំ សូមអភ័យទោសពី សំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ អ្នកអាន ដោយការគោរពស្មោះត្រង់ពីពួកយើងខ្ញុំនូវ រាល់កំហុសខុសឆ្គងទាំងឡាយណាដែលអាចកើត ចេញដោយអចេតនា និងសូមខន្តីអភ័យទោសដោយការគោរព ហើយយើងខ្ញុំទទួលស្វាគមន៍ក្នុងការរិះគន់បែប ស្ថាបនាដើម្បីកែលម្អបន្ថែមនូវមតិយោបល់ដើម្បីទទួលបាននូវកិច្ច ការសារណាបញ្ចប់ការសិក្សាមួយដ៏ល្អ។

ជាចុងក្រោយយើងខ្ញុំជានិស្សិតនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា ២០២០-២០២៤នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំមានចិត្តសប្បាយរីករាយ ក្នុងការយកប្រធានបទនេះ មកធ្វើ ការសិក្សាស្រាវជ្រាវឡើង ដើម្បីជាចំណងដៃសម្រាប់សាលា មិត្តអ្នកអាន និងខ្លួនឯងផ្ទាល់។ ហើយពួកយើងខ្ញុំ សូម ប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ សិស្សនិស្សិត សាស្ត្រាចារ្យ ជួបប្រទះនូវពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# **មាតិកា**

**ទំព័រ**

**សេចក្តីផ្តើម ........................................................................................ ១**

## **ជំពូកទី១**

## **សញ្ញាណទូទៅនៃការបង្វែរ**

**ផ្នែកទី១.ទិដ្ឋភាពទូទៅនៃការបង្វែរ........................................................................ ៦**

១.១ គោលបំណង ........................................................................................ ៦

១.២ គោលដៅ........................................................................................ ៨

១.៣ វិសាភាព........................................................................................ ៨

**ផ្នែកទី២.លក្ខខណ្ឌសារធាតុនៃការបង្វែរ........................................................................ ៩**

២.១ លក្ខខណ្ឌអប្បរមាបង្វែរ ........................................................................ ៩

២.២ លក្ខខណ្ឌវិនិច្ឆ័យការបង្វែរ ........................................................................១០

២.៣ វិធានការបង្វែរ........................................................................................១១

## **ជំពូកទី២**

## **ស្ថាប័នដែលទទួលបន្ទុកការអនុវត្តនៃនីតិវិធីបង្វែរ**

**ផ្នែកទី១. សមត្ថកិច្ចរបស់អយ្យការ ........................................................................ ១៣**

១.១ ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ........................................................................ ១៣

១.២ ការចេញដីកាផ្អាកការចោទប្រកាន់........................................................................១៤

១.៣ ការផ្តល់ដំណឹងដល់ជនរងគ្រោះ........................................................................១៥

**ផ្នែកទី២. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ..................................................... ១៥**

២.១ ការចេញដីការផ្អាកការស៊ើបសួរ ..................................................... ១៥

២.២ ការផ្តល់ដំណឹងដល់ជនរងគ្រោះ ..................................................... ១៦

**ផ្នែកទី.៣ អំណាចរបស់សាលាដំបូង និងសាលាឧទ្ធរណ៍ក្នុងការបង្វែរ .............................. ១៧**

៣.១ សមត្ថកិច្ចរបស់សាលាដំបូង ..................................................... ១៧

៣.២ សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ..................................................... ១៩

**ផ្នែកទី.៤ ភ្នាក់ងារសង្គមកិច្ច និងតួអង្គផ្សេងទៀត ..................................................... ២០**

## ជំពូកទី៣

## នីតិវិធីនៃវិធានការបង្វែរ

**ផ្នែកទី.១ ការរៀបចំផែនការបង្វែរ ..................................................... ២២**

១.១ ការពិចារណាក្នុងការបង្កើតផែនការបង្វែររបស់ភ្នាក់ងារសង្គមកិច្ច.................................. ២២

១.២ ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុក .............................................. ២៣

**ផ្នែកទី.២ ការអនុវត្តវិធានការបង្វែរ ..................................................... ២៣**

២.១ ការកែប្រែវិធានការបង្វែរ..................................................... ២៣

**ផ្នែកទី.៣ អានុភាពនៃការបង្វែរ..................................................... ២៤**

៣.១ ការបង្វែរទទួលបានជោគជ័យ ..................................................... ២៤

៣.២ ការបង្វែរទទួលបានបរាជ័យ ..................................................... ២៥

៣.៣ បញ្ហាប្រឈម ..................................................... ២៥

សេចក្តីសន្និដ្ឋាន ........................................................................................ ២៦

អនុសាសន៍ .................................................................................................... ២៨

ឯកសារយោង

ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយជាកំហុសរបស់ចារីផ្ទាល់ ។ ម៉្យាងវិញទៀតបទល្មើសក៏អាចត្រូវចាត់ទុកថាជាបាតុភូតអសកម្មក្នុងជីវភាពរស់នៅផងដែរ ពីព្រោះថាបទល្មើសបានជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់សង្គមដល់សេរីភាពរបស់ពលរដ្ឋ ។ ជាធម្មតាគេចាត់ទុកអំពើមួយ គឺជាបទល្មើសលុះត្រាតែអំពើនោះបង្ហាញនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់ការពារ ។ ជាទូទៅបទល្មើសគឺជាអំពើខុសនឹងសីលធម៌សង្គម ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងថែមទាំងបង្កឱ្យមានព្យសនកម្មគួរឱ្យកត់សម្គាល់សម្រាប់សង្គម ។ ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ការយល់ដឹងខុសត្រូវគឺជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ។ ប្រសិនបើក្មេងអាយុ ៥ ឆ្នាំ ម្នាក់បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយសារតែក្មេងអាយុ ៥ ឆ្នាំ នោះមិនមានសមត្ថភាពដឹងខុសត្រូវពីអំពើរបស់ខ្លួនឡើយ ។ ដោយឡែកចំពោះអនីតិជនដែលមានអាយុ ១៥ ឆ្នាំ វិញ ការអះអាងថាអនីតិជននោះមិនដឹងខុសត្រូវទាល់តែសោះនោះ គឺជាអំណះអំណាងមួយដែលពិបាកនឹងទទួលយកបាន ។ យោងតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនៅត្រឹមអាយុ ១៨ ឆ្នាំ បានន័យថាអនីតិជនដែលមានអាយុតិចជាង ១៨ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ទោះបីជាមានច្បាប់ក៏ដោយបទល្មើសខ្លះនៅតែកើតមានជាបន្តបន្ទាប់ក្រោមរូបភាពនិងលក្ខណៈផ្សេងៗគ្នា ដែលបទល្មើសខ្លះត្រូវបានប្រព្រឹត្តដោយនីតិជន រីឯបទល្មើសខ្លះទៀតត្រូវបានប្រព្រឹត្តឡើងដោយអនីតិជន ។ ដោយសារតែមិនមានប្រព័ន្ធយុត្តិធម៌ អនីតិជនរឹងមាំ និងការមិនទាន់មានច្បាប់ស្តីពីយុត្តិធម៌អនីតិជនជាក់លាក់រយៈពេលយូរធ្វើឲ្យកុមារជាជនល្មើសដែលមិនទាន់គ្រប់អាយុទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរួមទាំងកុមារដែលបានប្រព្រឹត្តបទល្មើសតូចតាចដូចជា លួច ការប្រើប្រាស់គ្រឿងញៀន ត្រូវបានកាត់ទោស និងផ្តន្ទាទោសដូចមនុស្សពេញវ័យដែរ ។ ទោះបី អប្បបរមានៃទោសត្រូវបានបន្ថយពាក់កណ្តាលសម្រាប់កុមារក៏វិធានការបន្ថយទោសនេះ មិនទាន់ឆ្លើយតប ទៅនឹងតម្រូវការករណីរបស់កុមារនៅឡើយ ។

ប្រព័ន្ធយុត្តិធម៌កម្ពុជានាពេលកន្លងមក ផ្តោតលើការផ្តន្ទាទោស ជាចម្បងដែលនាំឲ្យមិនសូវមានភាពជោគជ័យក្នុងការស្តារនីតិសម្បទានៅក្នុងសង្គម និងសហគមន៍ ។ មានការទទួលស្គាល់ជាទូទៅថា ការផ្តន្ទាទោស កុមារតាមរយៈដំណើរការរឿងក្តីព្រហ្មទណ្ឌ ពិតជាបណ្តាលឲ្យកុមារធ្លាក់ចូលទៅនឹងរឿងព្រហ្មទណ្ឌ បង្កឲ្យមានការប្រព្រឹត្តបទល្មើសជាថ្មី ហើយពេលខ្លះបទល្មើសកាន់តែធ្ងន់ធ្ងរទៀតផង ។ ហេតុដូច្នេះ ចាំបាច់ត្រូវតែ

មានអន្តរាគមន៍ឲ្យបានឆាប់ដែលអាចធ្វើទៅបានដើម្បីទប់ស្កាត់ ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មកុមារទាំងនោះទៅក្នុងសង្គមវិញប្រកបដោយប្រសិទ្ធភាព។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលបានរងចាំជាយូរមកនោះ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលត្រូវចូលជាធរមាននៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ ។ ច្បាប់នេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតប និងបំពេញបន្ថែមនូវភាពខ្វះចន្លោះក្នុងការអនុវត្តនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសស្របតាមបទដ្ឋានជាតិ និងអន្តរជាតិឲ្យកាន់តែមានលក្ខណៈច្បាស់លាស់ពេញលេញគ្រប់ជ្រុងជ្រោយសំដៅដល់ការទប់ស្កាត់ និងកាត់បន្ថយរាល់ទម្រង់នៃការប្រព្រឹត្តបទល្មើសក្នុងសង្គមប្រកបដោយប្រសិទ្ធភាព ។ ដែលមិនត្រឹមតែផ្តល់ការយល់ដឹងនឹងការអនុវត្តឲ្យកាន់តែច្បាស់ដល់មន្ត្រីតុលាការ និង មន្ត្រីអនុវត្តច្បាប់ក្នុងកិច្ចការពារនិងគ្រប់វិស័យយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជនប៉ុណ្ណោះទេ ប៉ុន្តែនៅបានធ្វើឲ្យមន្ត្រីអនុវត្តច្បាប់បានយល់ដឹងអំពីសិទ្ធិ និងនីតិវិធីបង្វែរ ដែលជាគោលការណ៍ចម្បងនឹងការធ្វើសមាហរណកម្មអនីតិជនប្រព្រឹត្តបទល្មើសទៅរស់នៅក្នុសហគមន៍ក្នុងគោលបំណងបម្រើឧត្តមប្រយោជន៍កុមារ ធ្វើឲ្យគ្រប់នីតិវិធីដែលពាក់ព័ន្ធនឹងអនីតិជនប្រព្រឹត្តបទល្មើសមានលក្ខណៈកុមារមេត្រី មានភស្តុតាងជាក់លាក់ក្នុងការចាត់វិធានការលើអនីតិជន ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនអនីតិជនជាជម្រើសចុងក្រោយ និង ខិតខំបញ្ចៀសនូវផលប៉ះពាល់ជាអវិជ្ជមានចំពោះកុមារជាពិសេសក្នុងបញ្ជីថ្កោលទោស។ ធ្វើឲ្យអនីតិជនប្រព្រឹត្តបទល្មើសបានយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងព្រំដែននៃការអនុវត្តសិទ្ធិរបស់ខ្លួនជាពិសេសយល់ដឹងពីនីតិវិធីដែលត្រូអង្គក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ប្រព្រឹត្តមកលើខ្លួនចំពោះអ្វីដែលត្រូវធ្វើនឹងត្រូវហាមឃាត់ ។ ជាជំហ៊ានដ៏សំខាន់មួយទៀតឆ្ពោះទៅរកកិច្ចការពារកុមារ ជាប្រព័ន្ធយុត្តិធម៌អនីតិជនដែលធានាការពារនឹងគោរពសិទ្ធិអនីតិជនទំនាស់នឹងច្បាប់ ។

## ២. ចំណោទបញ្ហា

ដោយមានការសង្កេតឃើញថា អនីតិជន ជាជនដែលមានសមត្ថភាពក្នុងការយល់ដឹងពីអំពើរបស់ខ្លួននៅមានកម្រិតនៅឡើយ ។ ទន្ទឹមនឹងការលើកឡើងខាងលើ មានបញ្ហាក៏ដូចជាចម្ងល់មួយចំនួនត្រូវបានចោទជាសំនួរថា តើនីតិវិធីបង្វែរអនីតិជនមានលំហូរនីតិវិធីដូចម្តេចខ្លះ ? តើនីតិវិធីបង្វែរស្ថិតនៅក្រោមដែនសមត្ថកិច្ចណាខ្លះ ? ហើយការបញ្ចប់នីតិវិធីបង្វែរមានអនុភាពដូចម្តេច ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះយើងខ្ញុំមានគោលបំណងមួយចំនួនដូចខាងក្រោម៖

១.ស្វែងយល់បន្ថែមទាក់ទងនឹងយុត្តិធម៌សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការទទួលបានសិទ្ធិជំនួយការបង្វែរនិងនីតិវិធីនៃការអនុវត្តគ្រប់ដំណាក់កាលលើអនីតិជន ។

២.ស្វែងយល់ឱ្យកាន់តែច្បាស់អំពីវិធានការក៏ដូចជានីតិវិធីដែលតុលាការអនុវត្តមកលើអនីតិជនអំពីការប្រកាស និងអនុវត្តទោសមកលើអនីតិជន ។

៣.ស្វែងយល់អំពីការការពារសិទ្ធិក៏ដូចជាផលប្រយោជន៍អនីតិជនដែលប្រព្រឹត្តបទល្មើសដោយការសិក្សាឱ្យបានច្បាស់លាស់ទៅលើអាយុ និងបទល្មើសរបស់អនីតិជន ជៀសវាងធ្វើឱ្យអនីតិជនបាត់បង់អនាគត។

៤. ចូលរួមចំណែកដល់ការគាំទ្រដល់ការស្តារនីតិសម្បទាចំពោះអនីតិជនដើម្បីអាចឱ្យអនីតិជនបានធ្វើការអប់រំ កែប្រែ ទទួលបានការគាំពារ ថែទាំ ឬ ការដាក់កម្រិតទោសឱ្យបានសមស្របនឹងលក្ខខណ្ឌអាយុជាក់ស្តែងរបស់អនីតិជន ។

៥.ចូលរួមការលើកកម្ពស់ការអនុវត្តច្បាប់ក៏ដូចជាការលើកកម្ពស់សិទ្ធិកុមារ ។

៦.ដើម្បីចូលរួមចំណែកក្នុងការការពារប្រយោជន៍អនីតិជន ដោយសារតែការអនុវត្តក្នុងសង្គមជាក់ស្តែងនូវមានចន្លោះប្រហោង តួយ៉ាងក្នុងដំណាក់កាលនគរបាលយុត្តិធម៌ដែលបានធ្វើការចាប់ ឬ ឃាត់ខ្លួនអនីតិជនមិនបានសិក្សាលម្អិតទៅលើលក្ខខណ្ឌដែលត្រូវឃាត់ខ្លួនអនីតិជន និងមិនបានជូនដំណឹងទៅឪពុកម្តាយឱ្យភ្លាមៗ។

៧.ដើម្បីទុកជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវលើប្រធានបទខាងលើបន្តឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ទំហំនៃការស្រាវជ្រាវនេះ មានកំណត់វិសាលភាពលើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ អនុសញ្ញាស្តីពីសិទ្ធកុមារ និងឯកសារបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិផ្សេងៗ ទៀតដែលពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជនដែលប្រព្រឹត្តបទល្មើស ។

នៅក្នុងការសរសេរសារណានេះ បានលើកឡើងតែអំពីការពាក់ព័ន្ធទាំងឡាយណា ដែលទាក់ទងជាមួយនឹងលំហូរនីតិវិធីបង្វែរអនីតិជន និងអានុភាពនៃការបញ្ចប់នីតិនីតិវិធីបង្វែរ ។

## ៥.សារៈប្រយោជន៍នៃការស្រាវជ្រាវ

ប្រធានបទដែលយើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវបានផ្តល់នូវសារៈសំខាន់ដូចជា៖

- មានសារៈសំខាន់ចំពោះសង្គមព្រោះកុមារជាធនធានក្នុងការបន្តវេនសម្រាប់អភិវឌ្ឍសង្គម កាលណាបើកុមារបន្តជាប់ពន្ធនាគារច្រើននោះសង្គមនឹងបាត់បង់ធនធាន ដូចនេះសង្គមត្រូវរិះរកគ្រប់មធ្យោបាយ ដោយការបង្កើតច្បាប់ យុទ្ធនាការនានា ដើម្បីការពារដល់កុមារគ្រប់ដំណាក់កាលទាំងអស់ និងមានសារៈសំខាន់ចំពោះប្រព័ន្ធច្បាប់ ព្រោះធ្វើឱ្យច្បាប់នូវកម្ពុជាកាន់តែមានអ្នកយល់ដឹង ហើយការអនុវត្តក៏កាន់តែមានប្រសិទ្ធិភាព។

- មានសារៈសំខាន់ចំពោះកុមារ គឺផ្តល់ឱ្យកុមារទទួលបាននូវការពារ និង ការពិចារណារកហេតុផលឱ្យបានច្បាស់លាស់មុននឹងសម្រេចដាក់ទោសលើកុមារ ដើម្បីជៀសវាងផលប៉ះពាល់ចំពោះអនាគតកុមារទៅថ្ងៃខាងមុខ

- មានសារៈសំខាន់ចំពោះខ្ញុំសម្រាប់ប្រធានបទនេះបានជំនួយស្មារតី និង ផ្តល់ជាប្រយោជន៍ដល់ចំណេះដឹងយ៉ាងច្រើន ព្រោះខ្ញុំបានស្វែងយល់ និង ស្រាវជ្រាវលើប្រធានបទនេះយ៉ាងយកចិត្តទុកដាក់ ។

- សារណានេះមានសារៈប្រយោជន៍ជាច្រើនចំពោះ អ្នកសិក្សា អ្នកអាន និង ស្រាវជ្រាវផ្ទាល់ ដោយសារតែសារណានេះបាន បកស្រាយយ៉ាងស៊ីជម្រៅពីលំហូរនីតិវិធីបង្វែរអនីតិជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងអានុភាពនៃការបញ្ចប់នីតិវិធីបង្វែរទៅលើអនីតិជនដែលប្រព្រឹត្តបទល្មើស ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវលើប្រធានបទនេះដើម្បីឱ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះមានលក្ខណៈវិទ្យាសាស្ត្រ និង មានកម្រិតជឿជាក់អាចទទួលយកបានដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោម៖

ការកំណត់អថេរដើម្បីកំណត់ទិសដៅស្វែករកទិន្នន័យយើងត្រូវកំណត់អថេរជាមុន ដែលមានទាំងអថេរឯករាជ្យ និងអថេរមិនឯករាជ្យ។

**អថេរឯករាជ្យ** សំដៅលើច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដូចជា៖

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

២. ក្រមព្រហ្មទណ្ឌ

៣. ក្រមនីតិវិធីព្រហ្មទណ្ឌ

៤. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

៥. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

៦. អនុសញ្ញាស្តីពីសិទ្ធិកុមារ

**អថេរមិនឯករាជ្យ** សំដៅលើយន្តការ និងដំណើរការនៃការអនុវត្តការងារយុត្តិធម៌អនីតិជនរបស់នាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន នៃអគ្គនាយកដ្ឋានព្រហ្មទណ្ឌ។

**ការប្រមូលទិន្នន័យ**

ត្រូវបានរៀបចងក្រងឡើងដោយមានការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា សុំមតិយោបល់ពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សច្បងនឹងត្រូវបានរៀបចំចងក្រងឡើងដោយឆ្លងកាត់ការស្វែងរកអត្ថបទច្បាប់ សៀវភៅ សារណា និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

**ការវិភាគទិន្នន័យ**

ទិន្នន័យដែលយើងខ្ញុំប្រមូលបាននឹងធ្វើការវិភាគតាមបែបពិពណ៌នា ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីលក្ខខណ្ឌច្បាប់ដែលទាក់ទងនឹងដំណើរការយុត្តិធម៌ក្នុងដំណាក់កាលនៃនីតិវិធីដែលអនុវត្តលើកុមារ រួមទាំងការអនុវត្តទោសលើកុមារដោយភាពសមស្របដើម្បីទុកជាជំនួយជួយដល់ការការពារផលប្រយោជន៍របស់កុមារពេលដែលសង្ស័យថាប្រព្រឹត្តបទល្មើស ឬ ត្រូវបានរកឃើញថា ប្រព្រឹត្តបទល្មើស ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាចំពោះប្រធានបទខាងលើស្តីអំពី **នីតិវិធីចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ** យើងទាំងពីរនាក់សូមធ្វើការបែងចែកជា ៣ ជំពូកធំដូចខាងក្រោម ៖

**ជំពូកទី១ ៖ សញ្ញាណទូទៅនៃការបង្វែរ**

**ជំពូកទី២ ៖ ស្ថាប័នដែលទទួលបន្ទុកការអនុវត្តនៃនីតិវិធី**

**ជំពូកទី៣ ៖ អានុភាពនៃការបញ្ចប់នីតិវិធីបង្វែរ**

# ជំពូកទី១

# សញ្ញាណទូទៅនៃការបខ្ទេរ

# ជំពូកទី១

# សញ្ញាណទូទៅនៃការបង្វែរ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនជា សមិទ្ធផលដ៏ធំធេងនៃកិច្ចសហប្រតិបត្តិការអស់រយៈពេលជិត១៨ឆ្នាំ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការ គណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័ន ព្រមទាំងដៃគូពាក់ព័ន្ធ ។ ដោយច្បាប់នេះក៏បានចែងពីវិធានការថ្មីមួយប្រភេទដែលហៅថា ការបង្វែរ ដែលអាចសម្រេចបានដោយ តំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍សម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ។ ការបង្វែរយើងអាចនិយាយបានថាជាយន្តការទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាពហើយក៏ជាយន្តការដំបូងដើម្បីគាំទ្រដល់កុមារមិនឱ្យប្រព្រឹត្តបទល្មើសជាថ្មីផងដែរ ។

ការបង្វែរជាវិធានការ ដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ [1]។ បើយោងតាមអត្ថបទមួយរបស់ UNICEF បានសរសេរថា៖ ការបង្វែរអាចត្រូវបានកំណត់តាមវិធីផ្សេងៗគ្នា ប៉ុន្តែពាក្យនេះតែងតែសម្តៅលើ វិធានការសម្រាប់ដោះស្រាយជាមួយកុមារដែលមានទំនាស់ជាមួយនឹងច្បាប់ដោយមិនចាំបាច់កាត់ក្តីជាផ្លូវការតាមផ្លូវតុលារការនោះទេ ។ ការបង្វែរអនីតិជនដែលមានទំនាស់ ឬ ជម្លោះជាមួយច្បាប់មានន័យថាពួកគេ (អនីតិជន) ត្រូវបានបញ្ជូនទៅអង្គការសហគមន៍ សេវាកម្ម ឬសកម្មភាពសមស្របណាមួយដែលអាចជៀសវាងពីផលប៉ះពាល់ អវិជ្ជមាននៃដំណើរការតុលាការ ដូចជាការផ្តន្ទាទោស ឬ ចៀសវាងការមានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសជាដើម។

## ផ្នែកទី១.ទិដ្ឋភាពទូទៅនៃការបង្វែរ

### ១.១ គោលបំណង

ការបង្វែរមានគោលបំណងកាត់បន្ថយផលប៉ះពាល់ដែលកើតឡើងពីការផ្តន្ទាទោសក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដោយអនុវត្តវិធានការផ្សេងដែលសមស្របសម្រាប់កុមារដែលប្រព្រឹត្តបទល្មើស។ ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម[2] ៖

[1] មាត្រា ៦០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[2] មាត្រា ៦៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- លើកទឹកចិត្តដល់អនីតិជនឱ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្ករឡើង
- ជំរុញឱ្យមានការសះជារវាងជនរងគ្រោះនឹងអនីតិជន
- លើកទឹកចិត្តឱ្យមានការជួសជុលការខូចខាត ការសងជម្ងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ សហគមន៍ ឬ សង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស

វិធានការនៃការបង្វែរនឹងផ្តល់ឱ្យនូវការអប់រំ ការកែប្រែអកប្បកិរិយារបស់អនីតិជនក្នុងនោះដែរច្បាប់នេះក៏បានកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយម៉ត់ចត់ដើម្បីកំណត់ឱ្យបានច្បាស់នូវអត្តិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន។

បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្តលើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។ ក្នុងន័យនេះគឺសំដៅលើវិធាន ឬ យន្តការទាំងឡាយណាដែលផ្តល់នូវការការពារដល់ឧត្តមប្រយោជន៍ជូនទៅដល់អនីតិជនក៏ដូចជាការប្រើប្រាស់នូវនីតិវិធីដោះស្រាយការពារសិទ្ធិអនីតិជនដើម្បីទទួលបានលទ្ធផលជាវិជ្ជមានប្រកបដោយប្រសិទ្ធភាព សម្រាប់អនីតិជនទំនាស់នឹងច្បាប់បច្ចុប្បន្ន និងទៅអនាគតដើម្បីកាត់បន្ថយចំនួនអនីតិជននៅក្នុងពន្ធនាគារ ។

នៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារបានចែងថា គ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងកុមារគឺត្រូវយកឧត្តមប្រយោជន៍របស់កុមារមកពិចារណាជាចម្បង។ ដូចគ្នានេះដែរគោលបំណងនៃការបង្វែរនេះក៏ត្រូវយកចិត្តទុកដាក់ និងពិចារណា រាល់សកម្មភាពដែលពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជនជាពិសេសធានានូវសិទ្ធិរស់រានមានជីវិតនិងការរីកចម្រើនលូតលាស់ជាអតិបរិមា។ វាអាចចូលរួមចំណែកជាវិជ្ជមានដល់ការអភិវឌ្ឍរបស់កុមារដោយអនុញ្ញាតឲ្យពួកគេទទួលខុសត្រូវចំពោះបទល្មើសរបស់ពួកគេដោយមិនចាំបាច់បញ្ជូនពួកគេទៅពន្ធនាគារ ម៉្យាងទៀតការចំណាយសោហ៊ុយទៅលើវិធានការបង្វែរក៏អស់តិចជាងការដាក់ពន្ធនាគារហើយក៏អាចកាត់បន្ថយសម្ពាធលើប្រព័ន្ធតុលាការ និងពន្ធនាគារដែលមានបន្ទុកធ្ងន់ធ្ងររួចទៅហើយ។ ផ្អែកទៅលើរបាយការណ៍ដែលមានចំណងជើងថា ការឆ្លើយតបនឹងអាទិភាពយុត្តិធម៌អនីតិជននៅតំបន់អាស៊ីប៉ាស៊ីហ្វិក( ADDRESSING JUVENILE JUSTICE PRIORITIES IN THE ASIA-PACIFIC REGION) បានសរសេរថា គោលបំណងនៃការ

បង្វែរ ឬវិធានផ្សេងៗ ក្រៅពីការឃុំខ្លួនគឺ៖ ផ្សះផ្សារវាងជនរងគ្រោះ និងជនល្មើស បញ្ចៀសការដកហូតសេរីភាពរបស់កុមារ លើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ និងធ្វើឱ្យកុមារមានការទទួលខុសត្រូវ ។[3]

## ១.២ គោលដៅ

គោលដៅគឺឱ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ[4] តែទទួលខុសត្រូវរដ្ឋប្បវេណី[5] និងកែប្រែខ្លួន ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្តិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។ បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្តលើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

យោងតាមខ្លឹមសារនៃច្បាប់នេះ គឺផ្តោតសំខាន់ទៅលើយន្តការទាំងឡាយណាដែលផ្តល់ឧត្តមប្រយោជន៍ជូនទៅដល់អនីតិជន ក៏ដូចជាការប្រើប្រាស់នូវនីតិវិធីដោះស្រាយមួយដែលមានការគោរពទៅដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរដែលជាកត្តាមួយ នាំឲ្យមានភាពមិនស្មើភាពគ្នាចំពោះមុខច្បាប់ រវាងការប្រព្រឹត្តនូវបទល្មើស ដូចគ្នា ដែលបង្កឡើងដោយនីតិជន និងអនីតិជន ។

## ១.៣ វិសាលភាព

ចំពោះច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាច្បាប់មួយដែលមានវិសាលភាពគ្របដណ្តប់លើករណីអនីតិជនដែលប្រព្រឹត្តបទល្មើស។ ប្រព័ន្ធយុត្តិធម៌កម្ពុជានាពេលកន្លងមកផ្តោតលើការផ្តន្ទាទោសជាចម្បងដែលនាំឱ្យមិនសូវមានភាពជោគជ័យក្នុងការស្តារនីតិសម្បទានៅក្នុងសង្គម និងសហគមន៍។ ជាទូទៅ ការផ្តន្ទាទោសអនីតិជនតាមរយៈដំណើរការរឿងក្តីព្រហ្មទណ្ឌ ពិតជាបណ្តាលឱ្យអនីតិជនធ្លាក់ចូលទៅនឹងរឿងក្តីព្រហ្មទណ្ឌ និងអាចបង្កឱ្យអនីតិជននោះមានការប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀត ហើយពេលខ្លះការប្រព្រឹត្តបទល្មើសថ្មី គឺអាចធ្ងន់ធ្ងរជាងបទល្មើសមុនទៀតក៏មាន។ ដូច្នេះហើយចាំបាច់ត្រូវតែមាន ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មកឆ្លើយតបបន្ថែមទៅលើរឿងក្តីអនីតិជន ព្រោះថាច្បាប់នេះបានផ្តល់ការគាំទ្រដល់ឧត្តមប្រយោជន៍អនីតិជនក៏ដូចជាផ្តល់កិច្ចការពារដល់អនីតិជនដែលប្រព្រឹត្ត បទល្មើស និងជួយអភិវឌ្ឍប្រព័ន្ធយុត្តិធម៌អនីតិជនឱ្យកាន់តែច្បាស់លាស់ប្រកបដោយនិរន្តភាពដែលផ្តោតលើការយកចិត្តទុកដាក់ចំពោះវិធានការបង្វែរ ការស្តារនីតិសម្បទា ដែលជា

[3] ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច, នៃផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ២០១៨-២០២០, បោះពុម្ពខែសីហា ឆ្នាំ២០១៨, ទំព័រទី២៣៥។

[4] មាត្រា ៥២ កថាខណ្ឌទី ៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[5] មាត្រា ២៨ កថាខណ្ឌទី ៤ មាត្រា ៣៨ កថាខណ្ឌទី ២ មាត្រា ៤៩ និងមាត្រា ៥២ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦

សកម្មភាពចម្បងជាជាងការដាក់ទណ្ឌកម្មក្នុងពន្ធនាគារ ។ បន្ថែមពីនេះ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់ជាជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារផងដែរគឺមានដូចជា វិធានការតាមដាន វិធានការពារ វិធានការឧបត្ថម្ភ វិធានការអប់រំ និងការដាក់ឱ្យបម្រើការងារសហគមន៍។ ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺត្រូវមានវិសាលភាពអនុវត្តដោយឥតលម្អៀងចំពោះ អនីតិជនដែលប្រព្រឹត្តបទល្មើសដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬ ស្ថានភាព ដទៃផ្សេងៗទៀតឡើយ។

## ផ្នែកទី២.លក្ខខណ្ឌសារធាតុនៃការបង្វែរ

កុមារដែលមានទំនាស់នឹងច្បាប់ទាំងអស់មិនមែនសុទ្ធតែអាចទទួលបាន ការបង្វែរទាំងអស់នោះទេ ពោលគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីទទួលបានការបង្វែរត្រូវតែមានលក្ខខណ្ឌកំណត់អំពីលក្ខខណ្ឌអប្បបរមា នៃការបង្វែរ និងលក្ខណវិនិច្ឆ័យ ។

### ២.១ លក្ខខណ្ឌអប្បរមាបង្វែរ

មុននឹងសម្រេចចិត្តធ្វើការបង្វែរអាជ្ញាធរទទួលបន្ទុកត្រូវប្រាកដថាលក្ខខណ្ឌអប្បបរមាដែលមានចែងក្នុងមាត្រា៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានបំពេញដោយលក្ខខណ្ឌអប្បបរមានោះរួមមាន៖

ក. ត្រូវមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬ បង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជននោះ។

ខ. អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។ អនីតិជនមានសិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯងឡើយ ។ ដូច្នេះតុលាការត្រូវពិនិត្យថ្លឹងថ្លែង និងបញ្ជាក់ថាការសារភាពកំហុសរបស់អនីតិជនគឺធ្វើឡើងដោយស្ម័គ្រចិត្តមិនមានការគំរាមកំហែង ឬ បង្ខិតបង្ខំឡើយ។ ដើម្បីវាយតម្លៃលើការសារភាពកំហុសសំខាន់ត្រូវពិនិត្យមើលលើការសិក្សាស្រាវជ្រាវផ្នែកចិត្តសាស្ត្រដែលបានអះអាងថាកុមារងាយនឹងសារភាពកំហុសដោយមិនត្រឹមត្រូវដោយសារតែការលួតលាស់ និងការយល់ដឹងរបស់កុមារនៅមានកម្រិត ។ ពួកគេងាយនឹងធ្វើតាមការណែនាំរបស់មន្ត្រីមានសមត្ថកិច្ច ។

គ. បទល្មើសដែលបានប្រព្រឹត្តគឺជាបទលហុ ឬបទមជ្ឈិម។ ជាប្រភេទបទស្រាលដែលអាជ្ញាធរទទួលបន្ទុកបង្វែរ អាចពិចារណា និងថ្លឹងថ្លែងថាអាចអនុវត្តការបង្វែរបាន ។ លើសពីនេះបទមជ្ឈិមដែលមានគ្មានទោសអាចត្រូវបានយកមកពិចារណាក្នុងការបង្វែរផងដែរ ។

ឃ. អនីតិជនយល់ព្រមឱ្យធ្វើការបង្វែរបន្ទាប់ពីបានពិគ្រោះយោបលជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរ អំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ[6]។

ក្នុងករណីដែលលក្ខខណ្ឌអប្បបរមាមិនត្រូវបានបំពេញទេ ប្រសិនបើស្ថិតក្នុងដំណាក់កាលអយ្យការ ព្រះរាជអាជ្ញាអាចបន្តនីតិវិធីទៅតាមច្បាប់ដោយធ្វើការចោទប្រកាន់ហើយបញ្ជូនទៅចៅក្រមស៊ើបសួរ ។ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរអាចពិចារណាដាក់អនីតិជនឱ្យស្ថិតក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ជំនួសឱ្យការឃុំខ្លួនបណ្ដោះអាសន្ន រងចាំការជំនុំជម្រះ ឬអាចត្រូវបានបញ្ជូនអនីតិជនទៅមណ្ឌលយុវនីតិសម្បទាដើម្បីស្តារនីតិសម្បទា ។

## ២.២ លក្ខខណ្ឌវិនិច្ឆ័យការបង្វែរ

ក្នុងករណីរឿងក្តីបំពេញទៅតាមលក្ខខណ្ឌអប្បបរមាខាងលើត្រូវបានបំពេញគ្រប់គ្រាន់ ហើយនោះត្រូវឆ្លងកាត់ដំណាក់កាលមួយទៀតនោះគឺ ការវិនិច្ឆ័យរបស់អាជ្ញាធរទទួលបន្ទុកសម្រាប់ការបង្វែរ ពោលគឺមុននឹងសម្រេចចិត្តថាធ្វើការបង្វែរ ឬមិនបង្វែរនោះ អាជ្ញាធរទទួលបន្ទុកត្រូវធ្វើការវិនិច្ឆ័យ និងពិចារណាលើកត្តាដូចខាងក្រោម[7]៖

- កាលៈទេសៈនៃបទល្មើស ។
- ស្ថានភាពនៃបទល្មើស ។
- បុគ្គលិកលក្ខណរបស់អនីតិជនដូចជាអាយុ កម្រិតនៃការយល់ដឹង បញ្ញា អត្តចរិតរបស់អនីតិជន។
- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។
- ព្យសនកម្មរបស់ជនរងគ្រោះ ។
- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម ។

## ២.៣ វិធានការបង្វែរ

វិធានការបង្វែរជាយន្តការដ៏សំខាន់មួយនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជន ដែលមានគោលបំណងដាក់អនីតិជនដែលមានទំនាស់នឹងច្បាប់ និងបានប្រព្រឹត្តកំហុសឱ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដោយមិនឆ្លងកាត់ដំណើកាត់ក្តីរបស់តុលាការ ការផ្តន្ទាទោស និងការអនុវត្តទោសនៅក្នុងពន្ធនាគារ ។

[6] មាត្រា ៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[7] មាត្រា ៦៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

វិធាននេះគឺជាសញ្ញាណគតិយុត្តថ្មីមួយនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជនរបស់កម្ពុជា និងត្រូវបានកំណត់ដោយច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។ អានុភាពនៃវិធានការបង្វែរជាប្រយោជន៍ដល់អនីតិជនក្នុងការទទួលបានការធ្វើសមាហរណកម្មឱ្យចូលទៅរស់នៅក្នុងសង្គម និងគ្រួសារវិញដោយពុំមានការរើសអើង។

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬ ច្រើនដូចខាងក្រោមសម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច[8]៖

-ចំណុចមួយឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ

- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ

- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងចិរវេលាមិនលើសពី ៦ (ប្រាំមួយ)ខែ

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះសម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ

- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសារជាថ្មី

- ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់ និងជួសជុលសំណងការខូចខាតទៅជនរងគ្រោះ

- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរត្រូវជានាប៉ារ៉ង់អនុវត្តសេចក្តីសម្រេច និងផែនការបង្វែរក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។ បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាននៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ហើយបន្ទាប់មក ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍ និង

[8] មាត្រា ៦៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

យោបល់របស់ខ្លួនទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ( តំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍) ។

ក្នុងករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ នោះគឺជាបរាជ័យក្នុងការអនុវត្តវិធានការបង្វែរ ។ ក្នុងករណីយ៉ាងដូច្នោះ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជនប្រសិនបើមានឱ្យចូលមកបង្ហាញខ្លួនក្នុងចិរវេលា មិនលើសពី ១៥ ថ្ងៃ ដើម្បីសាកសួរពីមូលហេតុដែលអនីតិជនមិនគោរពតាមវិធានការបង្វែរ ។ បន្ទាប់ពីបានពិចារណា និងពិគ្រោះយោបល់ជាមួយនឹងភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬ បន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

# ជំពូកទី២ ស្ថាប័នដែលទទួលបន្ទុក
# ការអនុវត្តនៃនីតិវិធីបខ្មែរ

# ជំពូកទី២

# ស្ថាប័នដែលទទួលបន្ទុកការអនុវត្តនៃនីតិវិធីបន្ធូរ

## ផ្នែកទី១. សមត្ថកិច្ចរបស់អយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន ។ ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជនត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្តីអនីតិជនទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាត ឬ មិនដាច់ខាតក្តី ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជនត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន[9]។ នៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជនមាត្រា ៦១ បានកំណត់ថា អាជ្ញាធរទទួលបន្ទុករួមមានតំណាងអយ្យការ ចៅក្រមស៊ើបសួរ និងចៅក្រមជម្រះ។

តំណាងអយ្យការ ជាអ្នកអាចស្នើសុំឱ្យធ្វើការបង្វែរបានគ្រប់ពេលតែត្រូវធ្វើមុនពេលការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ ក្នុងករណីដែលការរៀបចំផែនការបង្វែរត្រូវការពេលវេលាយូរ។ ចៅក្រមស៊ើបសួរអាចសម្រេចធ្វើការបង្វែរបានគ្រប់ពេលចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តបទមជ្ឈិម ប៉ុន្តែចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចបង្វែរនេះ មុនពេលចេញដីកាដំណោះស្រាយ ។ ក្នុងករណីនេះចៅក្រមស៊ើបសួរចេញដីកាសម្រេចផ្អាកនីតិវិធីស៊ើបសួរ ។ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ អាចសម្រេចធ្វើការបង្វែរបានគ្រប់ពេល ប៉ុន្តែមុនពេលមានការចេញសាលក្រមឬសាលដីកាលើអង្គសេចក្តី ។ ក្នុងករណីនេះចៅក្រមជំនុំជម្រះត្រូវចេញសាលក្រមបង្អង់រឿងទុក ។ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ក៏អនុវត្តបែបនេះដូចគ្នា ។

### ១.១ ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

មុននឹងប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន តុលាការត្រូវកំណត់ពី អាយុរបស់អនីតិជនឱ្យបានច្បាស់លាស់ ។ យោងតាមមាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បញ្ជាក់ឱ្យឃើញថាអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។ ចំណែកភស្តុតាងនៃអាយុរបស់អនីតិជនត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬ ឯកសារផ្សេងទៀតដែល

[9] មាត្រា ២៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អាចបញ្ជាក់បានអំពីកំណើត។ នៅក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាងដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់ រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ។

ការសង្ស័យពាក់ព័ន្ធនឹងអាយុកើតឡើងនៅពេលដែលកុមារស្ថិតនៅក្នុងការគ្រប់គ្រងរបស់នគរបាលយុត្តិធម៌ បញ្ហានេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា[10] ។

ព្រះរាជអាជ្ញាត្រូវពិនិត្យសំណុំឯកសារ និងពាក្យប្តឹងដែលខ្លួនបានទទួលដើម្បីផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ។ ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។

ប្រសិនការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋានអំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ[11] ។

ក្នុងករណីដែលតំណាងអយ្យការពិនិត្យឃើញថា អនីតិជននោះមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំគិតចាប់ពីថ្ងៃដែលគេត្រូវបានសង្ស័យថាអនីតិជននោះបានប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ការ និងប្រគល់អនីតិជននោះទៅកាន់តំណាងដែលច្បាប់បានកំណត់ ។

### ១.២ ការចេញដីកាផ្អាកការចោទប្រកាន់

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។ ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមក

[10] មាត្រា ១៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[11] មាត្រា ២៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។ ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។ ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។[12]

### ១.៣ ការផ្ដល់ដំណឹងដល់ជនរងគ្រោះ

ក្នុងករណីណាក៏ដោយការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជនហើយ ប្រសិនបើសមស្របត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។[13]

## ផ្នែកទី២. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

### ២.១ ការចេញដីកាផ្អាកការស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោសអាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរ សម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូក

[12] មាត្រា ២៨ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[13] មាត្រា ២៩ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះអាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ក្នុងករណី ដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី [14]។

## ២.២ ការផ្ដល់ដំណឹងដល់ជនរងគ្រោះ

ក្រោយពីទទួលបានដីកាបញ្ជូនសំណុំរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការបើកការស៊ើបសួរភ្លាម ហើយអនីតិជនដែលជាជនត្រូវចោទត្រូវមានមេធាវីក្នុងអំឡុងពេលស្តាប់ចម្លើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈមេធាវីហើយចៅក្រមស៊ើបសួរត្រូវទុកអំឡុងពេលសមរម្យមួយដើម្បីឱ្យមេធាវីធ្វើការសិក្សាទៅលើសំណុំរឿង និងពិភាក្សាជាមួយអនីតិជនមុនដំណើរការកិច្ចសួរចម្លើយ ។

នៅដែលពេលអនីតិជនបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យទៅលើអត្តសញ្ញាណរបស់អនីតិជនរួចត្រូវប្រាប់ឱ្យដឹងពីរឿងរ៉ាវដែលចោទប្រកាន់ ព្រមទាំងឈ្មោះបទល្មើសដែលច្បាប់បានកំណត់ និង

[14] មាត្រា ៣៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សិទ្ធិជាមូលដ្ឋានរបស់អនីតិជននៅក្នុងនីតិវិធីផងដែរ[15] ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពបើមិនដូច្នេះនឹងនាំឱ្យមោឃភាពនីតិវិធី ។

## ផ្នែកទី.៣ អំណាចរបស់សាលាដំបូង និងសាលាឧទ្ធរណ៍ក្នុងការបន្ទោស

### ៣.១ សមត្ថកិច្ចរបស់សាលាដំបូង

ចំពោះបទឧក្រិដ្ឋព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិមត្រូវមាន សមាសភាពចៅក្រមជំនុំជំរះចំនួន ៣ (បី) រូប ធ្វើការពិភាក្សា និងសម្រេចថានីតិជនមាន ឬគ្មានទោស។ ចំពោះបទលហុនៃអនីតិជន គឺមានតែចៅក្រមម្នាក់ដែលធ្វើការសម្រេចសេចក្តី។ តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនជា អាទិភាព ជាពិសេសរឿងដែលអនីតិជនកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ន។ លើសពីនេះទៅទៀតការពិភាក្សាដេញដោល និងប្រកាសសាលក្រមរបស់អនីតិជនត្រូវធ្វើនៅក្នុងសវនាការជាអសាធារណៈ ហើយមានតែបុគ្គលមានសិទ្ធិ និងកាតព្វកិច្ចពីផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីតែប៉ុណ្ណោះដែលមានសិទ្ធិក្នុងការចូលរួមក្នុងសវនាការបាន។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានការសំណូមពររបស់អនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាបុគ្គលទាំងនោះមិនបំរើឲ្យឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលសវនាការ។ តុលាការត្រូវប្រើនីតិវិធីកុមារមេត្រី ហើយក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញាអាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។

ចំពោះការឲ្យរួចផុតពីបទចោទក្នុងករណីដែលតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ និងដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីជាមានការប្តឹងពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់ទៅឱ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់នីតិជន។ ដូច្នេះ ក្នុងករណីតុលាការរកឃើញថាអនីតិជនបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីដែលតុលាការ ឃើញថាអំពើដែលចោទប្រកាន់លើអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់

[15] មាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬ អនីតិជនជាប់គ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និង បង្គាប់ឲ្យដោះលែងអនីតិជនភ្លាមទោះបីជាមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបានឃុំជននោះមិនត្រូវជាប់ឃុំពីបទល្មើសផ្សេងទៀត។ ជាមួយគ្នានេះជំនួយរបស់មេធាវីត្រូវតែមានជាដាច់ខាតក្នុងពេលសវនាការ។ ក្នុងករណីគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការនៅក្នុងលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ នៅពេលដែលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានហើយប្រាប់អំពីសិទ្ធិដែលមានដូចជា៖

- -សិទ្ធិទាក់ទងនឹងដំណាក់កាលនៃជំនុំជំរះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធជាមូលដ្ឋានក្នុងនីតិវិធី)
- -សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- -សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- -សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- -សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- -សិទ្ធិប្តឹងឧទ្ធរណ៍

ប្រសិនបើអនីតិជនអាចសារភាពនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តពេលជំនុំជម្រះ តុលាការត្រូវពិនិត្យ និងបញ្ជាក់ថាចម្លើយសារភាពដែលទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង គ្មានការបង្ខិតបង្ខំណាមួយ។ ប្រសិនបើចម្លើយសារភាពរបស់អនីតិជនផ្ទុយទៅនឹងបញ្ញត្តិខាងលើនេះ គឺមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ ចំពោះការសារភាពទទួលយកផែនការបង្វែរ មិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដទៃដែលសម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់ឡើយ។ ក្នុងពេលសវនាការ តុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។

សាលក្រមអាចធ្វើការប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ដែលការប្រកាសនេះត្រូវធ្វើឡើងជាអសាធារណៈ នៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ឬភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។

មិនតែប៉ុណ្ណោះសាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន។

## ៣.២ សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍

តុលាការជាន់ខ្ពស់ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ ដែលការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងរឿងអនីតិជន គឺសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ រីឯការជំនុំជម្រះលើបណ្តឹងសាទុក្ខដែលពាក់ព័ន្ធទៅនឹងរឿងក្តីអនីតិជនគឺជាសមត្ថកិច្ចរបស់តុលាការកំពូល។

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប ហើយតុលាការត្រូវតែផ្តល់អាទិភាពពិសេសដល់រឿងក្តីដែលមានអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន។ ការជំនុំជម្រះនេះ គឺត្រូវធ្វើក្នុងអំឡុងពេល ៣ (បី) ខែយ៉ាងយូរ គិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្នះបាន។ លើសពីនេះទៅទៀត ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលជំនុំជម្រះ សាលាឧទ្ធរណ៍ និងតុលាការកំពូល គប្បីពិចារណាអំពីការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងមានសេរីភាព។ ចំពោះអនីតិជនតុលាការជាន់ខ្ពស់ក៏មានអំណាចក្នុងការបង្វែរក្នុងករណី៖

- ភាពចលាចលដល់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួច
- អនីតិជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ

តុលាការជាន់ខ្ពស់ត្រូវសម្រេចសេចក្តីឱ្យបង្វែរ និងបង្គាប់ឲ្យដោះលែងអនីតិជនដែលកំពុងជាប់ឃុំនោះភ្លាម ទោះបីជាមានបណ្តឹងសារទុក្ខពីព្រះរាជអាជ្ញាក៏ដោយ។ ចំពោះនីតិវិធីរបស់តុលាការជាន់ខ្ពស់ គឺត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី និងត្រូវមានមេធាវីការពារជានិច្ច ព្រមទាំងពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។ ប្រសិនបើអនីតិជនមិនមានលទ្ធភាពពឹងពាក់មេធាវីបានទេ តុលាការត្រូវចាត់វិធានការឱ្យអនីតិជននោះ ហើយចំពោះការពិភាក្សាដេញដោល និងប្រកាសដីការឿងក្តីអនីតិជនត្រូវធ្វើក្នុងសវនាការជាសម្ងាត់។

## ផ្នែកទី.៤ ភ្នាក់ងារសង្គមកិច្ច និងតួអង្គផ្សេងទៀត

នៅក្នុងរឿងក្តីព្រហ្មទណ្ឌលើអនីតិជន យើងសង្កេតឃើញថាមានតួអង្គបីដែលមានវត្តមានជានិច្ច នៅក្នុងដំណាក់កាលនីមួយនៃនីតិវិធីដែលអនុវត្តចំពោះអនីតិជន ។ ប្រសិនបើអវត្តមានតួអង្គណាមួយក៏លំហូរនីតិវិធីនោះ មិនអាចប្រព្រឹត្តទៅបានដែរ ដូច្នេះហើយតួអង្គទាំងបីនេះមានសារៈសំខាន់ក្នុងការចូលរួមឲ្យការអនុវត្តនីតិវិធីអនុវត្តលើអនីតិជនប្រកបទៅដោយភាពរលូន និងសុក្រឹត្យភាព ជាពិសេសនៅពេលអវត្តមានជនណាមួយនឹងមានការចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់ពីមូលហេតុនៃការអវត្តមាននេះ។ ម៉្យាងវិញទៀតតួអង្គទាំងបី មានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយរបស់អនីតិជន និងត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃលើកំណត់ហេតុ ស្របតាមបទបញ្ញត្តិដែលបានចែង។ តួអង្គទាំងបីរួមមាន ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងកំណត់ដោយច្បាប់ អ្នកទំនុកបម្រុង និងមេធាវី។

- **ភ្នាក់ងារសង្គមកិច្ច៖** ដោយឡែកភ្នាក់ងារសង្គមកិច្ចក៏មានវត្តមានសំខាន់នៅក្នុងគ្រប់នីតិវិធីផងដែរ ដោយភ្នាក់ងារសង្គមកិច្ចមានតួនាទីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាជាបន្ទាន់ដល់អនីតិជនក្នុងដំណាក់ការស៊ើបអង្កេត។ ភ្នាក់ងារសង្គមកិច្ចត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអនីតិជនដើម្បីផ្តល់ការលើកទឹកចិត្ត អនីតិជនត្រូវទទួលសេវាការស្តារនីតិសម្បទា និងកិច្ចការពារថែទាំ ពីសំណាក់ភ្នាក់ងារសង្គមកិច្ច ដើម្បីចាត់វិធានការសមស្របទៅតាម សុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ តាមការស្នើសុំរបស់មន្ត្រីនគរបាល ដើម្បីធ្វើរបាយការណ៍ ទទួលអនីតិជនទៅព្រះរាជអាជ្ញា។ ករណីអនីតិជនពុំមានអ្នកតំណាងកំណត់ដោយច្បាប់ ភ្នាក់ងារសង្គមកិច្ចក៏ត្រូវមានភារកិច្ចត្រូវសុំតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននេះ។ ភ្នាក់ងារសង្គមកិច្ច ត្រូវបំពេញ តួនាទីក្នុងការប្រមូលផ្តុំព័ត៌មានទាក់ទងនឹងអនីតិជន រួមមានស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ លក្ខខណ្ឌនៃការរស់នៅរបស់អនីតិជនជាដើម ហើយជាចុងក្រោយភ្នាក់ងារសង្គមកិច្ចក៏ត្រូវមានភារកិច្ចក្នុងការរៀបចំផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរ។
- **អ្នកតំណាងដែលច្បាប់បានកំណត់** ៖ សំដៅទៅលើអ្នកមានអំណាចមេបាដូចជា ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលទូទៅរបស់អនីតិជន[16]។ អ្នកតំណាងកំណត់ដោយច្បាប់មានសិទ្ធិក្នុងការចាត់ចែងទំនុកបម្រុង ថែរក្សា និងការពារអនីតិជនដែលស្ថិតនៅក្រោមបន្ទុករបស់ខ្លួន។ ក្នុងនីតិវិធី

[16] មាត្រា ៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

នៃការអនុវត្តទៅលើការទទួលខុសត្រូវរបស់អនីតិជនតម្រូវឲ្យមានវត្តមានរបស់អ្នកតំណាងកំណត់ដោយច្បាប់ដើម្បីមកចូលរួមស្តាប់ចម្លើយរបស់អនីតិជនលើកលែងតែអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជនហើយការសម្រេចចិត្តនេះត្រូវឆ្លងកាត់ការពិគ្រោះយោបល់រវាងមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។ ករណីអ្នកតំណាងកំណត់ដោយច្បាប់មិនអាចចូលរួមបាន អ្នកទំនុកបម្រុងនឹងចូលរួមជំនួសដែលជាជនជ្រើសរើសដោយអនីតិជន ឬអាជ្ញាធរមានសមត្ថកិច្ចឆ្លងតាមការយល់ព្រមពីអនីតិជនដើម្បីទទួលខុសត្រូវអនីតិជនក្នុងនីតិវិធីអនុវត្ត។

- **អ្នកទំនុកបម្រុង** ៖ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។
- **មេធាវី** ៖ច្បាប់បានចែងពីសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដែលអនីតិជនមានសិទ្ធិទទួលបានជំនួយសេវាមេធាវីដោយជ្រើសរើស ឬ ចាត់តាំងដោយមិនយកកម្រៃនោះទេ។ មេធាវីត្រូវតែមានវត្តមានជានិច្ចក្នុងសវនាការ ដើម្បីចូលខ្លួនមកការពារសិទ្ធិ និងផលប្រយោជន៍របស់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ដោយបំពេញតាមវិជ្ជាជីវៈរបស់ខ្លួនឲ្យបានល្អ រក្សាការសម្ងាត់ និងឯកជនភាពរបស់អនីតិជន ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវី។ មេធាវីត្រូវមានការសន្ទនានឹងទំនាក់ទំនងជាមួយអនីតិជនតាមរយៈការប្រើនីតិវិធីកុមារមេត្រី ដើម្បីអាចឲ្យមេធាវីអាចកត់ត្រាកំណត់ហេតុ ស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ស្វែងរកភស្តុតាង និងសាក្សីជាសំអាង។ តុលាការនឹងទុកពេលវេលាសមស្របដើម្បីអាចឲ្យមេធាវីធ្វើលិខិតចម្លងសំណុំរឿងបានដែលសោហ៊ុយសម្រាប់ធ្វើការជាបន្ទុករបស់រដ្ឋ ក្នុងករណីតុលាការជាអ្នកជ្រើសរើស ប៉ុន្តែបើអនីតិជនជាអ្នកជ្រើសរើសនោះជាសោហ៊ុយជាបន្ទុករបស់មេធាវីផ្ទាល់។ មេធាវី ត្រូវធ្វើការសកម្មក្នុងការស្វែងរកភស្តុតាងដើម្បីដោះបន្ទុកដូចជាភស្តុតាងបញ្ជាក់ពីកង្វះធាតុផ្សំបទល្មើស បញ្ជាក់ពីអំពើយុត្តិកម្ម ( ការការពារដោយស្របច្បាប់ ) និងអភ័យឯកសិទ្ធជាដើម ដើម្បីបង្ហាញពីភាពសុចរិតរបស់កូនក្តី និងកាត់បន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ ។

# ជំពូកទី៣ នីតិវិធីនៃវិធានការ
# បង្វែរ

# ជំពូកទី៣

# នីតិវិធីនៃវិធានការបង្វែរ

ការបង្វែរគួរតែត្រូវបានគិតគូ និងសម្រេចឱ្យបានលឿនបំផុតដូចជានៅក្នុងដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរជាដើម។ ព្រោះបើទុកអនីតិជនរហូតដល់ដំណាក់កាលចៅក្រមជំនុំជម្រះនោះអនីតិជនអាចត្រូវបានឆ្លងកាត់ការឃុំខ្លួនបណ្ដោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលវាអាចប៉ះពាល់ទៅដល់ឧត្តមប្រយោជន៍របស់អនីតិជនដូចជា ការសិក្សា និងផ្លូវចិត្តជាដើម។ ម៉្យាងទៀតជាគោលការណ៍មូលដ្ឋាន ការឃុំខ្លួន អនីតិជនគឺជាជម្រើសចុងក្រោយ ។ ដូច្នេះបើក្នុងករណីដែលចៅក្រមស៊ើបសួរមិនសម្រេចឱ្យបង្វែរទេនោះ ចៅក្រមស៊ើបសួរអាចប្រើនីតិវិធីការឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសឱ្យការឃុំខ្លួន ហើយចៅក្រមជំនុំជម្រះអាចចេញដីការសម្រេចឱ្យបង្វែរ។

## ផ្នែកទី.១ ការរៀបចំផែនការបង្វែរ

ក្រោយពីទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្វែរផែនការបង្វែរ ហើយដោយផែនការនេះត្រូវសម្រេចក្នុងកំឡុងមិនលើស ១ ខែ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹង លើកលែងតែមានស្ថានភាពពិសេសមិនអាចជម្នះបាន ។

### ១.១ ការពិចារណាក្នុងការបង្កើតផែនការបង្វែររបស់ភ្នាក់ងារសង្គមកិច្ច

នៅក្នុងដំណាក់កាលនេះ ក្រោយពីបានទទួលបានដីកាសម្រេចឱ្យបង្វែរពីអាជ្ញាធរទទួលបន្ទុករួចមកភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ ដោយក្នុងការបង្កើតផែនការបង្វែរនេះ ធ្វើជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ហើយភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាមួយចំនួនដូចជា៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង

- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន

- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន

- សមាមាត្ររវាងផែនការដែលបានស្នើ ឬ ជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង

- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

បន្ទាប់ពីបានពិចារណា និង បង្កើតនូវផែនការបង្វែររួចរាល់ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនផែនការបង្វែរនោះ ទៅឱ្យអាជ្ញាធរទទួលបន្ទុកក្នុងការបង្វែរដើម្បីធ្វើការពិនិត្យ និងសម្រេច ។

### ១.២ ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុក

ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនផែនការបង្វែរដែលបានបង្កើតរួចទៅអាជ្ញាធរទទួលបន្ទុក ដើម្បីធ្វើការពិនិត្យ និងសម្រេចអំពីផែនការបង្វែរ ។ បន្ទាប់ពីទទួលបានផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ នៃថ្ងៃធ្វើការ ប្រសិនបើអាជ្ញាធរទទួលបន្ទុកមិនបានឆ្លើយតបត្រឡប់ទៅវិញក្នុងរយៈពេលដែលបានកំណត់នោះចាត់ទុកថាបានយល់ស្របតាមផែនការរបស់ភ្នាក់ងារសង្គមកិច្ច ។ ប្រសិនបើអាជ្ញាធរទទួលបន្ទុកមិនយល់ស្របលើវិធានការបង្វែររបស់ភ្នាក់ងាសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរជាថ្មី ។

## ផ្នែកទី.២ ការអនុវត្តវិធានការបង្វែរ

នៅក្នុងការអនុវត្តផែនការបង្វែរនេះ ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុក ត្រូវធានារ៉ាប់រងលើការអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលដែលទទួលបន្ទុកអនុវត្តផែនការបង្វែរត្រូវធ្វើរបាយការស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ និងឧបសគ្គដដែលកើតមាននៅពេលអនុវត្តផែនការទៅឱ្យភ្នាក់ងារសង្គមកិច្ច ហើយភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនបន្តនូវរបាយការណ៍ រួមទាំងយោបល់របស់ខ្លួនទៅកាន់អាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត។

### ២.១ ការកែប្រែវិធានការបង្វែរ

ក្នុងករណីដែលផែនការបង្វែរបានដាក់ឱ្យអនីតិជនអនុវត្តហើយរបាយការណ៍តាមដានវឌ្ឍនភាពពុំសូវឃើញមានប្រសិទ្ធភាពល្អនៅក្នុងអំឡុងពេលអនុវត្តផែនការបង្វែរនោះ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬ តាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងចិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

## ផ្នែកទី.៣ អានុភាពនៃការបង្វែរ

ប្រសិនបើការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ អាជ្ញាធរទទួលបន្ទុកបង្វែរ នៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការ[17] ( បើអាជ្ញាធរទទួលបន្ទុកបង្វែរគឺជាតំណាងអយ្យាការ ) ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់[18] (បើអាជ្ញាធរទទួលបន្ទុក បង្វែរ គឺជាចៅក្រមស៊ើបសួរ) សាលក្រម ឬសាលដីកាសម្រេចឱ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ( បើអាជ្ញាធរទទួលបន្ទុកបង្វែរ គឺជាតុលាការជំនុំជម្រះ នៅសាលាដំបូង ឬសាលាឧទ្ធរណ៍) ។

ឧទាហរណ៍ ៖ ពិសី ភេទប្រុស អាយុ ១៦ឆ្នាំ បានប្រព្រឹត្តអំពើលួច ហើយត្រូវបានឃាត់ខ្លួន និងបន្ទាប់មកទៀតត្រូវបានបញ្ជូនមកតំណាងអយ្យការ ។ ក្នុងករណីដូចនេះ តំណាងអយ្យការអាចចាត់វិធានការបង្វែរបាន ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់លើ ពិសី ពីបទលួចដែលជាបទមជ្ឈិមហើយពិសីក៏បានសារភាពទទួលកំហុស និងសុំទោសជនរងគ្រោះ ព្រមទាំងមានការយល់ព្រមរបស់ ពិសី ក្នុងការទទួលយកវិធានការបង្វែរ ។ តំណាងអយ្យការអាចចាត់វិធានការដូចជាតម្រូវឱ្យ ពិសី ត្រូវទៅសាលារៀនឱ្យបានទៀងទាត់តាមផែនការកំណត់មិន លើសពី ៦ខែ ។ ប្រសិនបើ ពិសី បានអនុវត្តតាមវិធានការនេះបានយ៉ាងត្រឹមត្រូវ នោះតំណាងអយ្យការនឹងចេញ ដីកាតម្កល់រឿងទុកឥតចាត់ការ ចំពោះបទល្មើស ដែលពិសីបានប្រព្រឹត្ត ។

### ៣.១ ការបង្វែរទទួលបានជោគជ័យ

ការបង្វែរទទួលបានជោគជ័យនៅពេលដែល អនីតិជនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនស្របទៅតាមវិធានបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច និងសម្រេចដោយអាជ្ញាធរទទួលបន្ទុកនោះបានត្រឹមត្រូវនិងចប់សព្វគ្រប់ ។ ប៉ុន្តែមិនមែនទាល់តែអនីតិជនបានបំពេញកាតព្វកិច្ចបានជោគជ័យគ្រប់ចំណុចនៃវិធានការទើបអាចទទួលបានជោគជ័យក្នុងការបង្វែរនោះទេ ពោលគឺច្បាប់មិនបានចែងបញ្ជាក់ពីអប្បបរមា ឬ អតិបរមា អំពីចំណុចនៃការអនុវត្តវិធានការនោះទេ។ ដូច្នេះហើយភ្នាក់ងារសង្គមកិច្ច និងអាជ្ញាធរទទួលបន្ទុកត្រូវក៏ពិចារណាបន្ថែមផងដែរ ក្នុងករណីដែលវិធានការបង្វែរមានច្រើនចំណុចដែលអនីតិជនត្រូវអនុវត្តប៉ុន្តែការអនុវត្តនោះជោគជ័យបានតែមួយចំនួន និងវិធានផ្សេងទៀតអនីតិជនមិនអាចបំពេញ ឬ អនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។

[17] មាត្រា ២៨ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[18] មាត្រា ៣៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ៣.២ ការបង្វែរទទួលបានបរាជ័យ

នៅក្នុងការអនុវត្តផែនការបង្វែរប្រសិន អនីតិជនជាសាមីខ្លួនមិនព្រមគោរពតាមកាតព្វកិច្ចដែលមានកំណត់ក្នុងផែនការបង្វែរដែលរៀបចំ និងបង្កើតឡើងដោយភ្នាក់ងារសង្គមកិច្ច ឬក៏ផែនការដែលបានកែប្រែនោះ អនីតិជននឹងត្រូវរាប់ថាបរាជ័យក្នុងការអនុវត្តវិធានការបង្វែរ។ ក្នុងករណីបរាជ័យបែបនេះអនីតិជនមិនអាចទទួលបានការធ្វើសមាហរណកម្មចូលទៅរស់នៅក្នុងសង្គម ឬ គ្រួសារវិញបានទេ ។

ប្រសិនបើការបង្វែរមិនទទួលបានជោគជ័យទេ ព្រះរាជអាជ្ញាត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច បុគ្គលដែលអនុវត្តផែនការបង្វែរ និងមេធាវីអនីតិជនមកសាកសួរអំពីមូលហេតុដែលមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងវិធានការបង្វែរ ។ ប្រសិនបើអនីតិជនចូលបង្ហាញខ្លួន និងបានផ្តល់មូលហេតុនៃការមិនគោរពតាមវិធានការបង្វែរ ព្រះរាជអាជ្ញាត្រូវពិចារណាអំពីទស្សនៈរបស់អនីតិជន និងពិភាក្សាពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីពិភាក្សារួច ព្រះរាជអាជ្ញាអាចចេញដីកាបង្វែរជាថ្មី ឬអាចបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ ។ ប្រសិនបើអនីតិជនមិនព្រមបង្ហាញខ្លួនតាមការកោះហៅរបស់ព្រះរាជអាជ្ញាដោយគ្មានមូលហេតុ ព្រះរាជអាជ្ញាត្រូវចាតុការបន្តតាមនីតិវិធីព្រហ្មទណ្ឌ។

## ៣.៣ បញ្ហាប្រឈម

វិធានការបង្វែរអនីតិជនក៏មានបញ្ហាមួយចំនួនដែលត្រូវប្រឈមលើ ការបរាជ័យក្នុងការបង្វែរសំដៅដល់ករណីដែលអនីតិជនមិនបានបំពេញ និងគោរពទៅតាមការអនុវត្តក្នុងវិធានបង្វែរ ឬនៅក្នុងវិធានការបង្វែរត្រូវបានកែប្រែ ។ នៅក្នុងការអនុវត្តវិធានការបង្វែរសម្រាប់អនីតិជនក៏មានបញ្ហាមួយចំនួនដែលត្រូវប្រឈមដូចជា ៖

ក. បញ្ហាប្រឈមទៅលើអាយុរបស់របស់ជនល្មើស

ការកំណត់អាយុត្រូវបញ្ជាក់ដោយភស្តុតាងនៃអាយុដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើត។ ក្នុងករណីពុំមានឯកសារឬមានមន្ទិលសង្ស័យ ឬមិនមានភាពច្បាស់លាស់លើលិខិតយថាភូតនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យាបាយផ្សេងទៀតដែលអាជ្ញាធរតុលាអាចជឿទុកចិត្តបាន។ ប្រសិនបើមានការសង្ស័យពាក់ព័ន្ធទៅនឹងអាយុរបស់អនីតិជន នគរបាលយុត្តិធម៌ត្រូវបញ្ជូនបញ្ហានេះទៅកាន់ព្រះរាជអាជ្ញា ប្រសិនបើមានមន្ទិលសង្ស័យបន្ទាប់ពីស៊ើបអង្កេតបឋមព្រះរាជអាជ្ញាត្រូវបញ្ជូនរឿងនេះទៅចៅក្រមស៊ើបសួរបន្តដើម្បីស្វែងរកការពិត ប្រសិនបើនៅមានមន្ទិលសង្ស័យទៀតចៅក្រមជំនុំជម្រះជាអ្នកស្វែងរកអាយុពិត។

ខ.កាសម្រេចរបង្វែរថ្មី

ប្រសិនបើការអនុវត្តវិធានការបង្វែរមិនទទួលបានជោគជ័យ អាជ្ញាធរទទួលបន្ទុកអាចសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យរបស់អនីតិជន។

គ. ស្ថានភាពពិសេស

នៅក្នុងការរៀបចំផែនការបង្វែរ ភ្នាក់ងារសង្គមកិច្ចមានរយៈពេលមួយខែសម្រាប់រៀបចំផែនការបង្វែរ លើកលែងតែមានស្ថានភាពពិសេស។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនិងបកស្រាយទៅលើប្រធានបទស្ដីពី នីតិវិធីបង្វែរអនីតិជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ យ៉ាងក្បោះក្បាយរួចមកបានបង្ហាញឱ្យយើងឃើញថា អនីតិជន គឺជាជនដែលស្ថិតនៅវ័យមួយដែលកំពុងលូតលាស់ទាំងផ្នែកសរីរាង្គ និងផ្នែកបញ្ញាស្មារតី គឺនៅមានកម្រិត ដែលជាហេតុធ្វើឱ្យអនីតិជនមិនមានសមត្ថភាពគិតពិចារណាទៅលើមជ្ឈដ្ឋានជុំវិញខ្លួនក៏ដូចជា ផលអវិជ្ជមានដែលកើតមានឡើងចំពោះខ្លួន។ ថ្វីត្បិតតែអនីតិជនមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌក៏បន្តែទន្ទឹមនឹងនោះ ក្រមព្រហ្មទណ្ឌតម្រូវឲ្យមានវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើស ។ ហេតុដូច្នេះប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស ជាគោលការណ៍ត្រូវប្រើវិធានការតាមដាន អប់រំ ការពារ ព្រមទាំងវិធានការផ្សេងៗទៀតដែលមិនមែនជាការផ្តន្ទាទោស ។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ក្រមព្រហ្មទណ្ឌ អនុញ្ញាតឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅបាន ដោយអនីតិជនត្រូវតែទទួលការផ្តន្ទាទោសតាមវិធានដោយឡែក ។

ដើម្បីឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់អនីតិជន យើងឃើញថា ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បង្កើតឡើងក្នុងគោលបំណងដើម្បីការពារផលប្រយោជន៍ និងផ្តល់ឱកាសសម្រាប់អនីតិជន កសាងខ្លួនចូលទៅក្នុងសង្គមជាថ្មី។ អនីតិជន គឺស្ថិតក្នុងស្ថានភាពមួយដែលកំពុងលូតលាស់ផ្នែកសមត្ថភាពស្មារតី ចិត្តគំនិត និងការពិចារណា រួមផ្សំជាមួយកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនទាំងអស់នេះជាមូលហេតុដែលនាំឲ្យមានការពិចារណាជាមូលដ្ឋានថា គួរតែផ្តន្ទាទោសទៅតាមច្បាប់កំណត់ ឬក៏ជ្រើសរើសយន្តការណាមួយមកអនុវត្តជាមួយប្រសិនបើចាត់វិធានការទៅតាមនីតិវិធីព្រហ្មទណ្ឌនោះអាចធ្វើឲ្យខាតបង់ ឧត្តមប្រយោជន៍របស់ អនីតិជន ។ ក្រឡេកមកមើល វិធានការបង្វែរវិញ គឺជាវិធានការមួយក្នុងចំណោមវិធានការផ្សេងទៀត ក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ដែលវិធានការនេះ អាចយកមកពិចារណាក្នុងការឲ្យអនីតិជនយកទៅអនុវត្តបានគ្រប់ដំណាក់កាល មិនថាក្នុងដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងជំនុំជម្រះទាំងក្នុងដំណាក់កាលសាលាដំបូង ឬសាលាឧទ្ធរណ៍ ។ ប្រសិនបើជ្រើសរើសយកវិធានការបង្វែរយកមកអនុវត្ត អនីតិជនអាចចៀសវាងអំពីការជាប់ពន្ធនាគារទាំងវ័យក្មេងនាំឲ្យមានស្នាមអាក្រក់ដិតជាប់អារម្មណ៍ ប្រឈមទៅនឹងការរើសអើង មានប្រវត្តិជាប់ពន្ធនាគារក្នុងបញ្ជីថ្កោលទោស ។ នីតិវិធីដែលអនុវត្តទោសព្រហ្មទណ្ឌចំពោះអនីតិជន ក៏មានលក្ខណៈពិសេសខុសពីនីតិជនផងដែរ ដោយហេតុថា នៅពេលដែលតុលាការប្រកាសទោសឱ្យជាប់ពន្ធនាគារ ទោសដែលអាចអនុវត្តចំពោះអនីតិជនបានគឺ ត្រូវស្ថិតនៅក្រោមអប្បបរមាដែលទាបបំផុត ឬត្រូវ

តែកម្រិតមកត្រឹមពាក់កណ្តាលនៃទោសដែលត្រូវអនុវត្តចំពោះ នីតិជន។ ទន្ទឹមនឹងនេះដែរ យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានលើកទឹកចិត្តក្នុងការយកអនីតិជនទៅរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាដែលមានលក្ខណៈដាច់ដោយឡែកពីនីតិជនហើយស្ថិតនៅអគារដោយមានការបែងចែកច្បាស់លាស់ទៅតាមភេទ ប្រភេទ ស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ជាជាងការយកអនីតិជនដាក់ក្នុងពន្ធនាគារ ។

សរុបមក នីតិវិធីបង្វែរអនីតិជនដែលប្រព្រឹត្តបទល្មើស គឺជាវិធានការមួយដែលគួរយកមកពិចារណាមកអនុវត្តសម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសក្នុងបទលហុ ឬបទមជ្ឈិម ក្នុងគ្រប់ដំណាក់កាលនៃនិតិវិធីព្រហ្មទណ្ឌ ដើម្បីជាឧត្តមប្រយោជន៍នានារបស់អនីតិជនក៏ដូចជាគោរពសិទ្ធមូលដ្ឋានទាំងឡាយដែលអនីតិជនត្រូវទទួលបានក្នុងអំឡុងពេលនៃដំណើការនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងទៀតនីតិវិធីបង្វែរនេះគឺស្ថិតក្នុងផែនការយុទ្ធសាស្ត្រដែលរៀបចំឡើងដើម្បីកសាងគ្រឹះដ៏រឹងមាំ និងប្រកបដោយចីរភាពសម្រាប់ប្រព័ន្ធយុត្តិធម៌ទំនើបនេះ។ នីតិវិធីបង្វែរអនីតិជនដែលប្រព្រឹត្តបទល្មើសនេះជាវិធានការប្រសើរក្នុងការអនុវត្តជាក់ស្តែង ជាជាងដាក់ទណ្ឌកម្មឲ្យជាប់ឃុំដែល ជាការលើកទឹកចិត្ត ក៏ដូចជាផ្តល់ឱកាសដល់អនីតិជនក្នុងការកែប្រែខ្លួន ក្លាយជាពលរដ្ឋល្អនាពេលអនាគត ។

# អនុសាសន៍

# អនុសាសន៍

នៅប្រទេសកម្ពុជានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី១៨ ឆ្នាំឡើងទៅ ។ តែទោះជាយ៉ាងនេះក្តី អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំក៏អាចត្រូវបានតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបានដែលប្រសិនបើកាលៈទេសៈ ឬបុគ្គលិកលក្ខណៈនៃអនីតិជននោះតម្រូវ ។ អនីតិជន មិនចាត់ទុកថាមានភាពចាស់ទុំ ឬទទួលខុសត្រូវគ្រប់គ្រាន់ និងវិនិច្ឆ័យលើអំពើរបស់ខ្លួនដូចមនុស្សពេញវ័យនោះទេ។ ប្រសិនបើរឿងក្តីអនីតិជនត្រូវបានដំណើរការដូចនីតិជននោះអនីតិជនប្រឈម និងហានិភ័យខ្ពស់ ដោយសារតែភាពខុសគ្នាទាំងស្ថានភាព អាយុ ឬភាពក្មេងខ្ចីរបស់អនីតិជន ។ ដូច្នេះហើយរាល់សកម្មភាពណាដែលពាក់ព័ន្ធនឹងអនីតិជនគឺត្រូវធានាឱ្យមានការគោរព និងពិចារណាលើគោលការណ៍ឧត្តមប្រយោជន៍របស់កុមារជាពិសេសធានានូវសិទ្ធរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមានៃកុមារ ។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦ សំដៅលើប្រព័ន្ធយុត្តិធម៌ដែលផ្តោតសំខាន់លើការបង្វែរ ជាងការដាក់ទណ្ឌកម្មឱ្យជាប់ឃុំ អនីតិជនអាចកសាងអនាគត និងក្លាយខ្លួនជាពលរដ្ឋល្អទៅថ្ងៃមុខ ហើយក៏មានការទទួលស្គាល់ជាអន្តរជាតិផងដែរថា ការបង្វែរចេញពីប្រព័ន្ធព្រហ្មទណ្ឌចេញពីកន្លែងឃុំឃាំងគឺជាយន្តការដ៏ល្អប្រសើរសម្រាប់កុមារមិនឱ្យប្រព្រឹត្តបទល្មើសសារជាថ្មីម្តងទៀត ។ ហេតុនេះហើយការដែលពិចារណាដាក់ឱ្យអនីតិជនទំនាស់នឹងច្បាប់ អនុវត្តវិធានការបង្វែរគឺជារឿងមួយដែលចាំបាច់ដោយវិធានការបង្វែរគឺជាសញ្ញាណមួយដែលថ្មីនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា ដែលណែនាំដោយច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។ ដោយបច្ចុប្បន្ននេះពុំសូវទាន់ឃើញមានការផ្សព្វផ្សាយអំពីវិធានការនេះច្រើនតាមបណ្តាញសង្គមនានានៅឡើយទេ ។ អនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានតុលាការធ្វើការផ្តន្ទាទោសតាមរយៈការដាក់ក្នុងពន្ធនាគារ ឬក៏ក្នុងមណ្ឌលយុវនីតិសម្បទា ឬមានទណ្ឌកម្មផ្សេងទៀត ត្រូវបានច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ បានផ្តល់ឱ្យនូវសិទ្ធិយ៉ាងច្រើនតាមរយៈក្រមព្រហ្មទណ្ឌ ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ រួមនឹងអនុសញ្ញាស្តីពី សិទ្ធិកុមារ និងច្បាប់ផ្សេងទៀតៗដែលពាក់ព័ន្ធនឹងកុមារ ។ យើងសង្កេតឃើញថានៅក្នុងនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមន្ត្រីនគរបាលយុត្តិធម៌តែងតែធ្វើការចាប់ខ្លួនអនីតិជនដោយមិនបានពិនិត្យទៅលើអាយុរបស់អនីតិជនហើយសកម្មភាពនៃការស៊ើបអង្កេតនេះ គឺតែងតែមិនស្ថិតនៅក្រោមនីតិវិធីកុមារមេត្រីដែលបណ្តាលឲ្យមានមោឃភាពនៃនីតិវិធី។ លើសពីនេះទៅទៀតដោយយើងឃើញថាយោងទៅតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនគឺតម្រូវឲ្យស្ថាប័នមានសមត្ថកិច្ចធ្វើការអនុវត្តទៅតាមនីតិវិធី ដែលបានចែងឱ្យបានហ្មត់ចត់ដើម្បីកំណត់ឲ្យច្បាស់លាស់នូវអទិភាពនៃបទល្មើសព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តដោយអនីតិជនដែលនីតិវិធីនេះអាចធ្វើឱ្យមាន

ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ពេលវេលា និងការសិក្សារបស់អនីតិជនជាប់សង្ស័យឬមិនបានប្រព្រឹត្តបទល្មើស។ ម្យ៉ាងវិញទៀតការអនុវត្តទោសចំពោះអនីតិជនគេសង្កេតឃើញថាមិនទាន់មានភាពត្រឹមត្រូវដែលស្របតាមច្បាប់ ស្តីពីយុត្តិធម៌អនីតិជនឡើយ ពោលទាក់ទងទៅនឹងវិធានការនៃការឃុំខ្លួនរបស់អនីតិជនឲ្យដាច់ដោយឡែកពីនីតិជននៅតាមពន្ធនាគារ គឺមិនទាន់មានការបែងចែកច្បាស់លាស់នៅឡើយ ដែលសរបញ្ជាក់ឲ្យឃើញពីភាពខ្វះចន្លោះនៃការអនុវត្តន៍របស់ភ្នាក់ងារសមត្ថកិច្ចទៅលើអនីតិជន។ មិនតែប៉ុណ្ណោះ មណ្ឌលយុវនីតិសម្បទា ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងអនីតិជនផ្តល់នូវការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំចិត្តសាស្ត្រ ការព្យាបាល ការថែទាំ ការការពារអនីតិជន ដើម្បីមានប្រយោជន៍សម្រាប់សង្គមជាតិនោះ មិនទាន់មានការបង្កើតឡើងនៅតាមរាជធានី-ខេត្តបានគ្រប់គ្រាន់នៅឡើយទេ ។

ម្យ៉ាងវិញទៀតកត្តាគ្រួសារក៏ជាចំណែកមួយក្នុងការទប់ស្កាត់អនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសផងដែរ មានន័យថានៅពេលដែលគ្រួសារមិនដែលបានបង្ហាត់បង្រៀនកូន និងពន្យល់បន្ថែមពីបញ្ហាផ្លូវច្បាប់ចំពោះកូន ថែមទាំងគ្រួសារនោះតែងតែមានអំពើហិង្សាក្នុងគ្រួសារនោះនាំឲ្យអនីតិជនយកគម្រូតាម ។ ដូចនេះសមាជិកក្នុងគ្រួសារត្រូវតែមានភាពស្និទ្ធស្នាលចំពោះកូន ហើយពួកគាត់ត្រូវតែបង្ហាត់បង្រៀនឲ្យ កូនធ្វើជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ និងត្រូវធ្វើការពន្យល់ពីបញ្ហាផ្លូវច្បាប់ចំពោះកូនរបស់ខ្លួនផងដែរ ។ អនីតិជន ជាទំពាំងស្នងឬស្សី កាលណាឬស្សីល្អ នោះទំពាំងក៏ល្អដែរ។ អនីតិជនងាយទទួលឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញខ្លួនណាស់ពីព្រោះការយល់ដឹងរបស់អនីតិជននៅមានកម្រិត ដូច្នេះហើយទើបអនីតិជនត្រូវការការយកចិត្តទុកដាក់ទទួលបានការអប់រំទទួលបានការទំនុកបម្រុងគ្រប់គ្រាន់ ដើម្បីសុខុមាលភាពកុមារដែលសមប្រពៃមួយ។

ជាចុងក្រោយក្រុមយើងខ្ញុំយល់ឃើញថា រាល់បញ្ហាដែលរៀបរាប់ខាងលើនេះទាមទារឲ្យមានដំណោះស្រាយល្អប្រសើរដើម្បីកែរតម្រូវនៅចំនុចដែលខ្វះខាតមួយចំនួនដូចជា៖

- នៅក្នុងការអនុវត្តជាក់ស្តែងក្នុងស្ថាប័នដែលទទួលបន្ទុកអនីតិជនមានការជំនុំជម្រះអនីតិជនជាសាធារណៈ ហើយរាល់ការបង្វែរនៅមិនទាន់អាចអនុវត្តបានឲ្យពេញលេញ ករណីខ្លះ មិនមានការបំបែកសំណុំរឿងនៅឡើយនោះទេ គឺធ្វើការជំនុំជម្រះ អនីតិជនជាមួយនឹងនីតិជនតែម្តង ។
- គប្បីពង្រឹងការផ្សព្វផ្សាយផ្នែកច្បាប់បន្ថែមដែលពាក់ព័ន្ធទៅនិងអនីតិជនឱ្យបានទូលំទូលាយទៅដល់មជ្ឈដ្ឋានទាំងអស់ រួមទាំងប្រជាពលរដ្ឋដើម្បីឱ្យមានការយល់ដឹង
- ជំរុញឲ្យមានការបង្កើតតុលាការជំនាញទៅលើរឿងក្តីអនីតិជន
- អនុវត្តនីតិវិធីទៅតាមដំណាក់កាលនីមួយៗ ដើម្បីធានាគ្រប់ដំណាក់កាលដែលប្រព្រឹត្តទៅពិតជាសមស្របទៅតាមនីតិវិធីច្បាប់

- ពង្រឹងនូវការអនុវត្តនីតិវិធីទៅតាមដំណាក់កាលនីមួយៗ ដើម្បីធានាថា គ្រប់ដំណាក់កាលដែលប្រព្រឹត្តទៅពិតជាសមស្របតាមលក្ខណៈនីតិវិធីកុមារមេត្រី
- ជំរុញឱ្យមានការបង្កើតមណ្ឌលយុវនីតិសម្បទានៅតាមបណ្តារាជធានី ខេត្ត ឱ្យបានគ្រប់គ្រាន់ ពិសេសគឺទៅតាមខេត្តនីមួយៗ
- ជំរុញឱ្យមានការបង្កើតតុលាការជំនាញលើរឿងក្តីអនីតិជន
- ជំរុញឱ្យស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នតុលាការ ដែលជាស្ថាប័នមួយក្នុងការកំណត់បទល្មើស ពិរុទ្ធភាពនៃបទល្មើស តាមនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ព្រមទាំងច្បាប់ស្តីពីយុត្តិធម៌អនីតិជនធ្វើការអនុវត្តដោយយកចិត្តទុកដាក់ជាទីបំផុតដោយស្របតាមការអនុលោមនៃច្បាប់បណ្តុះបណ្តាលដល់ជំនាញឯកទេសស្តីពីការអនុវត្តនីតិវិធីបែបកុមារមេត្រីសម្រាប់នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងតុលាការ រួមទាំងស្ថាប័នពាក់ព័ន្ធនឹងអនីតិជន
- ជំរុញនិងលើកទឹកចិត្តដល់មន្ត្រីពន្ធនាគារដែលស្ថិតនៅតំបន់សមត្ថកិច្ចគ្រប់គ្រងយកចិត្តទុកដាក់ចំពោះសិទ្ធិរបស់អនីតិជន ដែលត្រូវបានជាប់ឃុំ។

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០២០៨/ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រ១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៨០៧/ ០២៤/ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧

៤. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០១៦

៥. អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ២០០៩

៦. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

## សៀវភៅ និងស្នាដៃនិពន្ធ

១.លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២

២.លោក ប៉ែន ច័ន្ទសុខខេមរិទ្ធ ,សៀវភៅមេរៀនព្រហ្មទណ្ឌ

៣.សៀវភៅផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ ២០១៨-២០១៩

៤.សៀវភៅស្តីពីជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារកុមារនៅកម្ពុជារបស់អង្គការជីវិតនៅកម្ពុជា

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | កំណត់ហេតុទទួលវត្ថុចាប់យក |
| ០២ | កំណត់ហេតុសួរចម្លើយ |
| ០៣ | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យសើបសួរ |
| ០៤ | ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| ០៥ | ដីកាលើកលែងការចោទប្រកាន់ |
| ០៦ | សារាចរ ស្តីពីការអនុវត្តបទបញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍ |
| ០៧ | សារាចរ ស្តីពីការអនុវត្តបទបញ្ញត្តិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| ០៨ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| ០៩ | គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន |
| ១០ | ការបង្វែរ |

**ឧបសម្ព័ន្ធទី១**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
++++++

ក-1292/02-12-2015

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ 1324 អ.យ.ទ

## កំណត់ហេតុទទួលវត្ថុចាប់យក

ពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោង ប្រាំបី និងសាមសិប នាទី។

យើង ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាអ្នកទទួល។

លោក ជាមន្ត្រីនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ រួមជាមួយឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាជនសង្ស័យ។

បានពិនិត្យកិនកាតវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ឃើញដូចខាងក្រោម៖

√១- ម៉ូតូមួយគ្រឿងម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ (ម៉ូតូចាស់ ហើយមានតែតួ)

២- ញញួរចំនួន០២, ដែកដាប់ចំនួន០៣, ដែកគាស់ចំនួន០១, កន្ត្រៃចំនួន០៦, កូនកាំបិតចំនួន០២, កាំបិតប៉ុងតោចំនួន០៤, ដាវចំនួន០១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន០១។

៣- អង្គចងចាំចំនួន០១។

យើងធ្វើកំណត់ហេតុនេះ ទុកជាភស្តុតាង ដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ តាមផ្លូវច្បាប់តទៅ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោង ប្រាំបី និងសែសិបប្រាំ នាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

ជនជាប់សង្ស័យ អ្នកប្រគល់ អ្នកទទួល

បានឃើញ
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥
ជ.ព្រះរាជអាជ្ញា

[illegible] ថ្ងៃទី02-12-2015

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមានលោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជីកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់ភាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (ស្លាប់) ជាអនីតិជន ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្ដាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 ក្បាលឆ្លើស ពណ៌ក្រហម ទៅឈ្មោះ ខ្ញីយកជិះទៅធ្វើសកម្មភាពគាស់ទ្វារផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្ដង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូមខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាម៉ីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតម្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

**ឧបសម្ព័ន្ធទី៣**

៥/៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥
លេខ ៤៥៨៦ អ.យ.ទ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ របាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់[1] អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៤ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់ភូមិវាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្ដាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- ឈ្មោះ ហៅ ភេទប្រុស ប្រពន្ធឈ្មោះ (គេចខ្លួន)

៣- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៤- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៥- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៦- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

៧- ឈ្មោះ ភេទស្រី ប្ដីឈ្មោះ ហៅ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ[2] ÷**

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣និង១៥នាទី ទាបភ្លឺ ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ . . . . . ហៅ ឈ្មោះ ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្ដោងរ៉ឺម៉ក

---

[1] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[2] សេចក្តីសង្ខេបអង្គហេតុ

ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យឈ្មោះ បានធ្វើសកម្មភាពយកទួរណឺវីសឆ្កឹះសោទ្វារខាងមុខ ចំណែកជនសង្ស័យឈ្មោះ បានឆ្កឹះសោទ្វារខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ដុល្លារចំនួន៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនសង្ស័យបានគេចខ្លួនទៅផ្ទះរបស់ជនសង្ស័យឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ

បានទទួលប្រាក់ចំនួន ១លានរៀល។ ក្រោយមកជនសង្ស័យឈ្មោះ បានយកប្រាក់ចំនួន ៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនសង្ស័យឈ្មោះ ។ ចំណែកជនសង្ស័យឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន ១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយឃាត់ខ្លួនជនសង្ស័យពីរនាក់មានឈ្មោះ និងឈ្មោះ

ព្រមទាំងដកហូតវត្ថុតាងដូចមានក្នុងកំណត់ហេតុ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

អំពើរបស់ឈ្មោះ ឈ្មោះ ហៅចយ ឈ្មោះ ឈ្មោះ និងឈ្មោះ ជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ -៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>ហេតុដូច្នេះសម្រេច</u>

- បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ[៣]

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

---

[៣] ឈ្មោះជនត្រូវចោទ

**ឧបសម្ព័ន្ធទី៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ត្រីស៊ើបសួរ ( ៣ )

លេខ ២១ ជ.ជ

## ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៥៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នលេខ៣៥៦,៣៥១,៣៦៤(ក)ដយដ ចុះថ្ងៃទី....២៦.... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលីវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ . ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រូស ឃុំក្រូស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិក្រូស ឃុំក្រូស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្តីឈ្មោះ ទោសពីមុនគ្មាន ជាជីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១៦៣E០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦ ក្រឡាបញ្ជី

ជ.ព្រះរាជអាជ្ញា

រាជធានីភ្នំពេញ ថ្ងៃទី ១៥...ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី៥**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរសើុបសួរ ( ៣ )

លេខ 210 ដជ

## ដីកាលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

### សំអាងហេតុ

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ៦៨ អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

**ឧបសម្ព័ន្ធទី៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :..០៣ [illegible]/១៤

## សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៩៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសជាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៥-ត្រូវពិចារណាលើរបាយការណ៍ ឬព័ត៌មានរបស់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបទប្បញ្ញត្តិ នៃមាត្រា ២២៧-២២៨-២២៩ និង ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ-ព្រះរាជអាជ្ញា**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ពិនិត្យឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការស្នើសុំដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-បន្ទាប់ពីទទួលបានដីកាបង្គាប់ ដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវចាត់វិធានការដូចខាងក្រោម ៖

-ណែនាំជនត្រូវចោទអំពីរបៀបដែលត្រូវអនុវត្តកាតព្វកិច្ច ដូចបានកំណត់ក្នុងដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ

-ណែនាំដល់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរឲ្យត្រួតពិនិត្យ តាមដាននិងធ្វើរបាយការណ៍តាមការកំណត់ ។

៣-ក្នុងករណីចៅក្រមស៊ើបសួរ បង្គាប់ឲ្យជនត្រូវចោទទៅបង្ហាញខ្លួន នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវបង្គាប់ទៅអង្គភាពនោះឲ្យចាត់វិធានការដូចខាងក្រោម ៖

-រៀបចំឲ្យមានសៀវភៅសម្រាប់ចុះវត្តមានជនត្រូវចោទ ដែលត្រូវមកបង្ហាញខ្លួនតាមការកំណត់របស់ចៅក្រមស៊ើបសួរ

-ចាត់ភ្នាក់ងាររបស់ខ្លួនឲ្យតាមឃ្លាំមើលសកម្មភាពរបស់ជនត្រូវចោទ ក្នុងការបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ជនត្រូវចោទ (វត្តមាន និងសកម្មភាព) ក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់ជូនទៅព្រះរាជអាជ្ញា។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០១៤

អង្គ វង្សវឌ្ឍនា

**ចម្លងជូន ៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០១.៦០០៣.៩៧/១៤

## សារាចរ
## ស្តីពី
## ការអនុវត្តបទបញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ២២៣ ដល់ មាត្រា ២៣០ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តមិនទាន់បានល្អប្រសើរ។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមស៊ើបសួរ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-ត្រូវគិតអំពីវិធានការនៃការត្រួតពិនិត្យ និងឃ្លាំមើលដើម្បីធានាថា ជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។

ករណីនេះ ចៅក្រមស៊ើបសួរគប្បីចាត់តាំងបុគ្គលណាមួយដែលមានសមត្ថកិច្ច អាចជួយតាមឃ្លាំមើល និងធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ គប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

៣-ត្រូវផ្តល់ដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះមួយច្បាប់ ឲ្យដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬគ្រប់បុគ្គលដែលត្រូវបានចាត់តាំងក្នុងមូលដ្ឋានដែលជនត្រូវចោទត្រូវទៅរស់នៅ ដើម្បីអនុវត្តកាតព្វកិច្ច ក្រៅពីជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

៤-ត្រូវណែនាំជនត្រូវចោទ ដែលត្រូវបានដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យយកដីកាសម្រេចនេះ ទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលត្រូវបានចាត់តាំង ក្នុងមូលដ្ឋានដែលខ្លួនត្រូវទៅរស់នៅ។

៨.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រូស ឃុំក្រូស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិក្រូស ឃុំក្រូស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្ដីឈ្មោះ ទោសពីមុនគ្មាន ជាជនជាតិខ្មែរ។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ជាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ុយហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១៦ឪ០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦ ក្រឡាបញ្ជី

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

**ឧបសម្ព័ន្ធទី៨**

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ឧបសម្ព័ន្ធទី៩**

# ជំពូកទី ២
# គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

## មាត្រា ៥._ គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរព គោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្ដីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្ដល់ឱកាសឲ្យអនីតិជនសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្ដីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជ-អាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្ដល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្ដី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវដ្ដប្បវេណីរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

**ឧបសម្ព័ន្ធទី១០**

# ជំពូកទី ១០
# ការបង្វែរ

## មាត្រា ៦០.- ការបង្វែរ

ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ ។

## មាត្រា ៦១.- អាជ្ញាធរទទួលបន្ទុកបង្វែរ

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។

## មាត្រា ៦២.- គោលបំណងនៃការបង្វែរ

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជាវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស ។

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL